អ្នកស្រែខឹងណាស់គក់ទ្រូង គប់ស្មាថា អាចោរទន្សាយពុតខ្លួន អញស្មានថាជាវាង៉ាប់មែន ឥឡូវវាបោលចូលព្រៃបាត់ព្រាងើយ អើអត់ឲ្យ ថ្ងៃក្រោយគង់តែភ្លេចត្រចៀកមកត្រូវអន្ទាក់អញ ទៀតមិនខានទេ ។

(សម្រួលពីសំរាំង)

សំនួរ

៨១– ចូរស្រង់យកសកម្មកិរិយា ដែលនៅក្នុងអត្ថបទនេះ ហើយចង្អុលប្រាប់បទកម្ម ដាក់នៅក្នុងវង្វង់ក្រចក [ ឧ. ស៊ី (សំណាប) ] ? ចូរសម្ពន្ធកិរិយាសព្ទក្នុងឃ្លា ម្ចាស់សំណាបមកឃើញទន្សាយ . : . . . ចូលទៅវិញ ?

៨២- អ្នកយល់ឃើញដូចម្ដេចបានជាអ្នកស្រែគក់ទ្រូងគក់ស្មា ? តើអ្នកអាចបន្ទោសថាអ្នកស្រែជាមនុស្សធ្វេសប្រហែសឬទេ ? ក្នុងអត្ថបទនេះ អ្នកអាចសំគាល់ថាទន្សាយស្លាប់មែន ឬ មិនស្លាប់ ? តើពាក្យណាខ្លះដែលអាចទាញយកមកបញ្ជាក់ ?

៨៣. សទិសស័ព្ទ ពុត (កុ ពុតត្បុត) ៗ (ន) ថ្ងៃ ពុធ ៗ ពុទ្ធ (ន.) អច្ឆរិយបុគ្គលមួយរូបដែលបានត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ហៅថាព្រះពុទ្ធ ៗ

៨៤. សរសេរតាមសូត្រ ឧឆ្លាៈ បជាប់អង្គាក់

៨៥- តែងសេចក្ដី

ចូរអ្នកអធិប្បាយអំពីការបរបាញ់ដែលអ្នកធ្លាប់បានទៅប្រព្រឹត្តក្នុងកាលណាមួយ តើមិត្តកើតកយ៉ប្មួយក៏មានសង្វេគចំពោះសត្វ ចូរបង្អុលឲ្យឃើញច្បាស់

# មេរៀនទី១២

## កាល

### អតីតកាល

(អំពើធ្វើរួចហើយ)

(ពីម្សិល)



១-អាណោ បានខាំក្មេងម្នាក់ ដាប់ដាចមុខមាត់

### បច្ចុប្បន្នកាល

(អំពើកំពុងធ្វើ)

(ឥឡូវ)



២-អាណោកំពុងខាំក្មេងម្នាក់ ហែកខោ

### អនាគតកាល

(អំពើមិនទាន់ធ្វើ)

(ស្អែក, ខានស្អែក)



៣-អាណោចាំតែនឹងខាំសត្វមកបៀតបៀនហ្វូងចៀម

## ពិនិត្យ

១- អំពើណាដែលបានសំរេចរួចទៅហើយ កាល

ដែលបានធ្វើកន្លងផុតពីថ្ងៃមុនមកដូច្នេះ   កាលដែលកន្លងផុតមកហើយហៅថាអតីតកាល ត្រូវមានពាក្យថាបាននាំមុខ ហើយត្រូវមានពាក្យថាហើយ នៅចុងកិរិយាស័ព្ទជួនកាលគេថា .(កិ.)...ហើយឬបាន...(កិ.)...ហើយ

២- កាលដែលកិរិយាស័ព្ទកំពុងតែធ្វើមិនទាន់កន្លងផុត កម្មដែលធ្វើនោះមិនទាន់បានសំរេច តែនៅកំពុងធ្វើ កាលដូច្នេះត្រូវមានពាក្យថា „កំពុង,រមែង.... នៅមុខកិរិយាស័ព្ទ ឬ ប្រើកិរិយាស័ព្ទទោលក៏បាន ហៅថាបច្ចុប្បន្នកាល

៣– កាលដែលគេត្រូវធ្វើនេះមិនទាន់មកដល់ គឺកាលនៅខាងមុខ កម្មដែលត្រូវធ្វើនោះមិនទាន់បានធ្វើទេ តែមុខតែធ្វើក្នុងពេលខាងមុខដូច្នេះកាលនោះ ហៅថាអនាគតកាលត្រូវប្រើពាក្យថា"នឹង„នៅមុខកិរិយាស័ព្ទ.

## សង្ខេប

| | |
|---|---|
| បានខាំ | សកម្មកិរិយា អតីតកាល ឯកវចនៈមានអាណោជាប្រធាន |
| កំពុងខាំ | សកម្មកិរិយា បច្ចុប្បន្នកាល ឯកវចនៈ មានអាណោជាប្រធាន |
| នឹងខាំ | សកម្មកិរិយា អនាគតកាល ឯកវចនៈ មានអាណោជាប្រធាន |

## មេរៀន

កាល គឺពាក្យសំរាប់សំគាល់ឲ្យដឹងពេលក្នុងការ-និយាយស្តី ដើម្បីឲ្យដឹងថាឥឡូវនេះ ពីអង្កាល ឬដល់ទៅអង្កាល ក្នុងភាសាខ្មែរ កាលចែកដោយសង្ខេបមាន ៣ គឺ-បច្ចុប្បន្នកាល អតីតកាល និងអនាគតកាល

១- បច្ចុប្បន្នកាល ពេលដែលកំពុងតែមាននៅចំពោះមុខ

មេរៀន(គ)

១. កូនសិស្ស កំពុងលេងក្នុងសួនច្បារ

២- អតីតកាល ពេលដែលកន្លងហួសទៅហើយ

១- ពីម្សិលមិញ សាស្ត្រាចារ្យបានឲ្យទៅដល់សិស្សហើយក្នុងទីចំពោះមុខចង្ហាងសាលា

៣- អនាគតកាល ពេលដែលមិនទាន់មកដល់ គឺពេលនៅខាងមុខ

១- ស្អែកមាតាបិតាខ្ញុំនឹងអញ្ជើញទៅមើលប្រាសាទអង្គរវត្ត

វេយ្យាករណ៍ ពាក្យស័ព្ទ

សំនួរ

៨៦- កាលមានអត្ថន័យដូចម្ដេច? បើចែកដោយសង្ខេប កាលមានប៉ុន្មាន? គឺអ្វីខ្លះ? កាលមួយៗមានន័យដូចម្ដេច? តើមានពាក្យអ្វីខ្លះសំរាប់ឲ្យដឹងកាលមួយៗនោះ?

ការហាត់

៨៧- ចូរធ្វើកិរិយាស័ព្ទខាងក្រោមនេះ ឲ្យសមតាមកាលទាំងបី ដូចឧទាហរណ៍ ធ្វើ: កំពុងធ្វើ (បច្ចុប្បន្ន) បានធ្វើហើយ(អតីត) នឹងធ្វើ (អនាគត)

សិក្សា, ស្វាធ្យាយ, រៀន, ទន្ទេញ, មើល, រត់, ដេក, សិង, ឆាន់, សោយ ។

## អត្ថបទ ខ្លាឃ្មុំនឹងដើមពង្រ

មានខ្លាឃ្មុំមួយ កំពុងតែដេកជាសុខក្រោមដើមពង្រ លុះដេកបន្តិចទៅ មែកពង្រមួយក៏បាក់ធ្លាក់មកលើក្បាលខ្លាឃ្មុំនោះ ។ ខ្លាឃ្មុំនោះ ខឹងនឹងដើមពង្រណាស់ ក៏ចងអាឃាតថា អាដើមពង្រនេះ អញកំពុងតែដេកស្រួលៗ វាមិនគួរបាក់ធ្លាក់មកលើអញ ឲ្យបានក្តីទុក្ខវេទនាមានសភាពយ៉ាងនេះសោះ ពីថ្ងៃនេះទៅ អញនឹងចងពៀរវេរ ទាល់តែបានសម្រេច ។

ខ្ញុំកំពុងតែដើរទៅ    បានជួបនឹងអ្នកបររទេះម្នាក់ កំពុងត្រាប់រកឈើធ្វើភ្លៅរទេះ  លុះបានស្តាប់ខ្ញុំសាសព្ទ ហើយក៏ដើរតម្រង់ទៅរកដើមពង្រនោះ ។

ឯដើមពង្រជាលំនៅរុក្ខទេវតា ។ កាលឃើញមនុស្ស មកបំរុងនឹងកាប់ដើមពង្រដូច្នោះ  ក៏ដឹងថាមុខជាខ្ញុំញុះ. ញង់មិនខាន  ទើបប្រាប់ថា  បើអ្នកកាប់ដើមពង្រយកបាន ហើយ  ត្រូវទៅរកខ្ញាញ់ខ្ញុំមកលាបនឹង តតែជាប់បាន យូរ ។

ឯអ្នកបររទេះបានឮដូច្នោះហើយ  ក៏ដើរទៅរកខ្ញុំ ដើម្បីនឹងប្រហារយកខ្ញាញ់លាបភ្លៅរទេះ ។ ខ្ញុំដល់នូវ ក្តីមរណៈ  ហើយចងពៀរហូតមកដល់សព្វថ្ងៃនេះ

(សម្រួលពីគតិលោក ខ្សែ៨)

សំនួរ

៨៨— ចូរស្រង់យកកិរិយាសព្ទដែលប្រើក្នុងកាលទាំងបី ?

ហើយបង្អុលប្រាប់កាល ដោយដាក់នៅក្នុងរង្វង់ក្រចក ?

ចូរសម្ពន្ធ នាម កិរិយាសព្ទក្នុងឃ្លាទីមួយអត្ថបទខាង

លើនេះ ? ចូរធ្វើឃ្លាទីមួយឲ្យទៅជាអតីតកាល ?

៨៩– អ្នកយល់ឃើញដូចម្ដេច ចំពោះសត្វខ្លាឃ្មុំ ? តើអ្នក

ឲ្យឈ្មោះថាជាមនុស្សបែបណា ? តើទេវតាដែលប្រាប់ដូច្នោះ

គួរថាជាមនុស្សអ្នកព្រះញាណឬទេ ?

លេខបញ្ជី :

៩០– អក្ខរាវិរុទ្ធ

អាឃាត (ប្រកបទឹងតទឹងជបាទដូចគ្នា) ។ វៀរ (រ)។

ប្រហារ (រ) ។

៩១– សរសេរតាមសូត្រ ខ្លាឃ្មុំនិងដើមពទ្រ

៩២ – តែងសេចក្ដី

ចូរអធិប្បាយ អំពីរុក្ខជាតិណាមួយ ដែលមានម្លប់ត្រឈឹងត្រឈៃ ហើយចូរអ្នកនិយាយអំពីសេចក្ដីរីករាយរបស់អ្នក ដែលកំពុងតែដើរអស់កំលាំង ដោយកំដៅ ហើយបានទៅជួបនឹងម្លប់ដូច្នេះ ៗ

# មេរៀនទី ១៣

## វាចក

កត្តុវាចក | កម្មវាចក




១- ឆ្មាកំពុងចាប់ កណ្ដុរឈ្មោល

២- កណ្ដុរដែលឆ្មា ចាប់

### ពិនិត្យ

១- កិរិយាសព្ទណាដែលមានបទប្រធាន សំរេចខ្លួនឯងគឺធ្វើនូវអំពើផ្ទាល់ខ្លួន ដូចជានៅក្នុងឃ្លាទី ១ ថា ឆ្មា

កំពុងចាប់កណ្តុរ ឆ្មា ជាបទប្រធាន ជាអ្នកធ្វើ (គឺចាប់) កណ្តុរ ជាអំពើដែលត្រូវធ្វើ ជាបទកម្ម កំពុងចាប់ជាកិរិយាប្រាប់ដំណើរធ្វើរបស់សត្វឆ្មា ប្រយោគបែបនេះហៅថា កត្តុវាចក (គឺបទប្រធានធ្វើកិរិយាខ្លួនឯង)

២- ឯកិរិយាសព្ទកន្សោមទី ២ គឺបទកម្ម ស្ទុះទៅធ្វើជាប្រធានបទប្រធានត្រឡប់ទៅធ្វើជាបទកម្មវិញ ដូចជាឃ្លាថា កណ្តុរ ដែលឆ្មាចាប់ កន្សោមនេះពិតមែនតែកណ្តុរជាប្រធាន ប៉ុន្តែកណ្តុរមិនមែនធ្វើអំពើទេ គឺឆ្មា ជាអ្នកធ្វើនូវអំពើ ឯកណ្តុរជាអ្នករងអំពើ របស់កិរិយាសព្ទ ចាប់ ប្រយោគដូច្នេះហៅថា កម្មវាចក

## សង្ខេប

១– កន្សោមថា ឆ្មាកំពុងចាប់កណ្តុរ ជាប្រយោគ កត្តុវាចក

២ –កន្សោមថាកណ្តុរដែលឆ្មាចាប់ ជាប្រយោគកម្មវាចក

| | |
|---|---|
| កណ្ដុរ | សាធារណនាមឯកវចនៈបុំល្លិង្គ ប្រធានរបស់ចាប់ |
| ដែលឆ្មា | សាធារណនាម ឯកវចនៈបុំល្លិង្គ អនុកិរិតកត្តាគុណ |

(កិរិយាសព្ទ) ចាប់

## មេរៀន

ពាក្យដែលសំគាល់ប្រាប់នាទី ឬដំណើររបស់កិរិយាសព្ទ ហៅថា វាចក ។

វាចក បើចែកដោយពិស្ដារមាន ៤ យ៉ាងគឺ កត្តុវាចក កម្មវាចក, ភាវវាចក, ហេតុកត្តុវាចក និងហេតុកម្មវាចក ។ ប៉ុន្តែក្នុងវេយ្យាករណ៍ថ្នាក់ឧត្ដមដ្ឋាននេះ គួរណាស់តែរៀនត្រឹមតែកត្តុវាចក និងកម្មវាចកប៉ុណ្ណោះ ។

១- កត្តុវាចក កិរិយាសព្ទ ដែលជាកត្តុវាចក លុះណាបទប្រធានជាអ្នកធ្វើនូវអំពើ

មេរៀន (ត)

១. បុគ្គល ឲ្យទានដល់សមណព្រាហ្មណ៍ ដោយចិត្តជ្រះថ្លា មុខជាបានបុណ្យច្រើន

២– តាមរចនា កិរិយាស័ព្ទដែលជាកម្មវាចក លុះតែបងប្រធានដាប់តែធ្វើអំពើ ទៅទទួលធ្វើជាបទកម្មវិញ

១. ទាន ដែលបុគ្គល ឲ្យដល់សមណព្រាហ្មណ៍ ដោយចិត្តជ្រះថ្លា មុខជាបានបុណ្យច្រើន ។

ចំណាំ ក្នុងប្រយោគកម្មវាចក ត្រូវប្រើពាក្យ (ដែលនឹងគឺ) នៅមុខនាមដែលជាអ្នកធ្វើអំពើ ។ តែក្នុងទីខ្លះដែលមិនមែនប្រើក្នុងប្រយោគកម្មវាចកឡើយ

វេយ្យាករណ៍ ពាក្យស័ព្ទ

សំនួរ

៨៣– ដូចម្ដេចដែលហៅថា វាចក? មានប៉ុន្មានយ៉ាង ?

កត្តុវាចក និង កម្មវាចក ខុសគ្នាដូចម្ដេច ?

៩៤- ចូរធ្វើប្រយោគខាងក្រោមនេះឲ្យទៅជាប្រយោគកម្មវាចក

១. បុគ្គលឲ្យទាន ដល់អ្នកក្រ (ប្រយោគកត្តុវាចក)

ទានដែលបុគ្គលឲ្យដល់អ្នកក្រ (ប្រយោគកម្មវាចក)

១- កូនសិស្ស មើលសៀវភៅ

២- អ្នកស្រែ ដឹកក្របី

៣- ក្មេង ស៊ីនំ

៤- ក្របី ស៊ីស្មៅ

៥. ម្ដាយខ្ញុំ ទិញកង់ ឲ្យជារង្វាន់ដល់ប្អូនខ្ញុំ

៩៥- ចូរធ្វើប្រយោគកម្មវាចក ទៅជាកត្តុវាចក:

១- សត្វដែលព្រានប្រមាញ់យកមកលក់នៅផ្សារ

២- ពស់ ដែលក្មេង វាយ

៣- ព្រះសង្ឃ ដែលឧបាសកនិមន្ត មកបង្សុកូល

៤- ឈើ ដែល គេកាប់ យកមកធ្វើផ្ទះ

៥- ឈើ ដែលដុពុកខ្ញុំអូសយកមកគរនៅក្រោយផ្ទះ

អត្ថបទ ទុងនិងត្រី

មានសត្វទុង ១ជាសត្វប្រកាន់សក្កាយទិដ្ឋិ ។ ថ្ងៃមួយសត្វទុងចេញស្វែងរកចាប់ត្រីជាអាហារ លុះហែលទៅបានឃើញត្រីក្អិត១ ហែលនៅក្បែរខ្លួន ក៏ចឹកត្រីក្អិតនោះ សត្វទុងកាលបើ បានឃើញត្រីដែលអញចឹកបានមកតូចដូច្នោះ ក៏គិតថាអញជាសត្វបក្សីរូបធំ ត្រូវតែបរិភោគត្រីធំៗដែរ ដូចត្រីរ៉ស់·ប្រា-ព្រួល ជាដើម ទើបសមយសស័ក្តិអញ ។ តាត្រីក្អិតរូបល្អិតដែលអញចាប់បាននេះមានរូបក៏តូចពេកណាស់ អញគួរតែលែងហើយទៅរកចាប់ត្រីធំៗវិញ ។

សត្វទុងស្វែងរកមួយថ្ងៃជួបតែត្រីតូចៗ ចឹកចោល ៗ ដោយយល់ថាមិនគួរនឹងយសស័ក្តិអញជាបក្សីធំ ៗ ពេល

កាន់តែល្អបណាស់ទៅហើយ ខ្ទុងឃ្លានអាហារមហិមា នឹងបែរទៅរកត្រីដែលបោះចោលទៅនោះពុំអាចបានឡើយ ហើយក៏កើតមានវិប្បដិសារី ។

សត្វខ្ទុងកាលបើរកអាហារមិនបានបរិភោគដូច្នោះទើត គួបចិត្តថា អញនេះហៅពេញជាជាតិខុស មិនសន្សំត្រី តូចៗ ស៊ីផ្សំគ្នា គិតប្រមាណថាអាតូចៗមិនសមនឹងខ្លួន ចាំរកត្រីធំៗឲ្យសមនឹងយសស័ក្តិខ្លួន ដល់មិនបានត្រីធំក៏ អត់ស៊ីដូច្នោះទៅ ។

សំនួរ

៩៦- ចូរស្រង់យកប្រយោគកត្តាបកក្នុងអត្ថបទខាងលើនេះ?

ចូរធ្វើប្រយោគថា "សត្វខ្ទុងកាលបើបានឃើញ ត្រី. . . . . . . . ទើបសមស័ក្តិអញ" ឲ្យទៅជា ប្រយោគកត្តាបក ?

៩៧- ក្នុងអត្ថបទខាងស្រុងនេះ ចូរអ្នកឲ្យគតិដល់បុគ្គល

ពួកណា ? សត្វទុំជាសត្វប្រកាន់ទិដ្ឋិដូចម្ដេច ?

៩៨- អក្ខរាវិរុទ្ធ

បរិភោគ (ប្រកបនឹងគ) ប្រមាណ (ប្រកបនឹងណ) មិនត្រូវមានមូសិកទន្តលើ មា ពីព្រោះ ប្រជាអឃោសៈកាច់ មា ជាឃោសៈ ឲ្យទៅជាអឃោសបានទៅហើយ) ។

៩៩- សរសេរតាមសូត្រ ទុងជឹងគ្រី

១០០- តែងសេចក្ដី

ចូរអ្នកនិយាយអំពីកំហុសរបស់អ្នកដែលអ្នកធ្វើឲ្យកន្លងមកហើយ ក្នុងពេលដែលអ្នកស្វែងរកបេះផលានុផល ឃើញផ្លែនោះតូច ៗ អ្នកមិនយកឬក៏វត្ថុនោះតិចក៏មិនយកដែរ តើសេចក្ដីស្ដាយក្រោយរបស់អ្នកដូចម្ដេច តើអ្នកគួរឲ្យដំបូន្មានខ្លួនឯងដូចម្ដេច?

# មេរៀនទី១៨

## បុរិសសព្វនាម



១. ខ្ញុំ ប្រាប់ឯងថា វា នៅតូចណាស់ !

២. ឯង ដឹកដៃវាផង

៣. លឿនឡើង ! វា យំហើយ

៤. យើង រត់ចោល វា

### ពិនិត្យ

១- ពាក្យដែលប្រើជំនួសនាមដែលគេនិយាយរួចម្ដង ហើយ គេមិនបាច់ចេញឈ្មោះនាមស័ព្ទនោះទៀតគេត្រូវ

ប្រើបុរិសសព្វនាមវិញ ដូចពាក្យថា ខ្ញុំ គេប្រើដើម្បីជំនួសនាមដែលសំគាល់ឈ្មោះបុគ្គលដែលត្រូវនិយាយទៅរកគេទៀត ដែលមិនចេញឈ្មោះខ្លួន ត្រូវចេញថាខ្ញុំ ហៅថា ឧត្តមបុរិសសព្វនាម

២- ពាក្យដែលប្រើជំនួសនាមដែរ គេត្រូវប្រើជំនួសបុគ្គលដែលគេកំពុងនិយាយទៅរកក្នុងទីចំពោះមុខ គេមិនបាច់ចេញឈ្មោះបុគ្គលនោះទេ គេគ្រាន់តែចេញឈ្មោះថា ឯង នាង ហង , លោក . . . . ជាដើមដូច្នេះ ហៅថា មជ្ឈិមបុរិសសព្វនាម

៣- ពាក្យដែលគេប្រើជំនួសនាមទៀត តែប្រើជំនួសបុគ្គលដែលគេនិយាយ ដោយនៅកំបាំងមុខ គេមិនចេញឈ្មោះបុគ្គលនោះទេ នាំឲ្យស្ងួនសេចក្តី គេត្រូវប្រើពាក្យថា វា , គាត់ , អា , នាង , លោក ជាដើម ហៅថា បឋមបុរិសសព្វនាម

ចំណាំ ក) បុរិសសព្វនាមមួយ ៗ មានពីរយ៉ាងគឺ ឯកវចនៈនឹងពហុវចនៈ។ បើពហុវចនៈត្រូវប្រើពាក្យថា ទាំងឡាយ, ទាំងពួង, ទាំងអស់... ។

ខ) ត្រូវចេះប្រើតាមថ្នាក់, ខ្ពស់, ទាប, កណ្ដាល លោកសង្ឃ ស្ដេច, មន្ត្រី ។

មេរៀន

បុរិសសព្វនាម គឺពាក្យដែលសំរាប់ប្រើជំនួសនាមដែលបាននិយាយរួចមកហើយ ឬដែលកំពុងនិយាយ ដើម្បីកុំឲ្យស្ទួនពាក្យ ៗ បុរិសសព្វនាម ចែកជា៣ យ៉ាងគឺ ឧត្ដមបុរិសសព្វនាម, មជ្ឈិមបុរិសសព្វនាម នឹងបឋមបុរិសសព្វនាម

១-ឧត្ដមបុរិសសព្វនាម ប្រើជំនួសបុគ្គលដែលត្រូវនិយាយទៅរកបុគ្គលឯទៀត ៗ

ទ - ខ្ញុំមិនយល់ទោសខ្លួន ក៏ឆ្លើយថាប្របខ្ញុំនេះព្រះអង្គ

## មេរៀន (ត)

សាងឲ្យមានធ្មេញចង្កូមដ៏មុត . . . (គតិលោក)

២- មជ្ឈិមបុរិសសព្វនាម ជំនួសបុគ្គលដែលគេត្រូវនិយាយទៅរកក្នុងទីចំពោះមុខ

ខ. ព្រះឥសូរក៏ត្រាស់ទៅឧដ្ឋវិញថា "ម្ដេចចៅឧដ្ឋ រូបកាយឯងសព្វថ្ងៃនេះស្រួលបួលហើយឬ. . . (គតិលោក)

៣- បឋមបុរិសសព្វនាម ប្រើជំនួសបុគ្គលដែលគេត្រូវនិយាយ ខ. សត្វឧដ្ឋឆ្លើយថា "ព្រះអង្គ រូបកាយខ្ញុំនេះមានកវែងអាចអើតស៊ីស្លឹកឈើខ្ពស់បាន . . ."

(គតិលោក)

បុរិសសព្វនាមមានដូចខាងក្រោមនេះ

## មេរៀន (គ)

| | ឯកវចន | ពហុវចន |
|---|---|---|
| ១ ឧត្តមបុរស | ខ្ញុំ, ខ្ញុំបាទ ខ្ញុំឯង, អញ, អាត្មាភាព, អាត្មា, នាងខ្ញុំ | យើង, យើងខ្ញុំ, យើងទាំងអស់គ្នា ពួកខ្ញុំ, ពួកយើង . . . . |
| មជ្ឈិមបុរស | ឯង, លោក, ទ្រង់ ព្រះអង្គ នាង, ហង, អា, អ្នក . . . | ឯងទាំងអស់គ្នា, អស់លោក នាងទាំងឡាយ, ហងរាល់គ្នា |
| បឋមបុរស | វា, គេ, នាង, លោក, ព្រះអង្គ ទ្រង់ . . . | វាទាំងឡាយ, គេទាំងអស់ អស់ទាំងនាង . . . . |

វេយ្យាករណ៍ វាក្យសព្ទ

សំនួរ

១០១. បុរសសព្វនាមមានន័យដូចម្តេច? ចែកជាប៉ុន្មានយ៉ាង?

បុរសសព្វនាមមួយៗនោះ មានន័យដូចម្តេច? ចូរលើកឧទាហរណ៍?

ការហាត់

១០២. ចូរតែងឃ្លានឹងបុរសសព្វនាមខាងក្រោមនេះ

ព្រះអង្គ, ទ្រង់, អាត្មាភាព, ហង, ឯង, វា, អញខ្ញុំ, ខ្ញុំបាទ

## អត្ថបទ ព្រះឥសូរនឹងពានរ

កាលព្រះឥសូរត្រាស់សួរ ស្វាជាមុនថាហៃចៅពានរ រូបកាយចៅឯងដែលយើងសាងឲ្យ មានអវយវៈយ៉ាងនេះ សព្វថ្ងៃនេះចៅឯងគាប់ចិត្តពេញចិត្តហើយឬ នៅមានក្ដីទាស់ត្រង់ណាខ្លះ ប្រាប់ចៅថាទៅមើល យើងនឹងកែប្រែជាថ្មីទៀត ។

ឯពានរមើលទោសខ្លួនមិនឃើញ សំគាល់ថាឥតទាស់ ក៏តបទៅវិញថា សូមទានលំអងធូលីព្រះបាទ សាងរូបកាយខ្ញុំជាស្វាដូច្នេះ មានដៃវែងជើងវែង លុមទងបេះផលានុផលបានស្រួល ៗ ព្រះអង្គសាងរូបខ្ញុំនេះពេញចិត្តហើយ តែសូមព្រះអង្គមេត្តាកែសត្វខ្លាឃ្មុំវិញ ព្រោះរូបវាមិនសមរម្យទេ គឺមុខប្រែបួញ រោមខ្មៅងិតឥតមានកន្ទុយនឹងបក់ ... ។ ព្រះឥសូរបានឮស្វាថាដូច្នោះ ក៏ត្រាស់សួរខ្លាឃ្មុំថា ហៃចៅអច្ឆជាតិ រូបកាយចៅឯង ដែលយើងសាងឲ្យយ៉ាងនេះ តើ

ជាទីគាប់ចិត្តទៅឯងហើយឬ។ នៅត្រង់ណា ចូរថាមកយើង
នឹងកែឲ្យ ។

(សម្រួលពីគតិលោក)

សំនួរ

១០៣- ចូរស្រង់យកបុរិសសព្វនាម ដែលមាននៅ
ក្នុងអត្ថបទខាងលើនេះ? ហើយចូររៀបឲ្យត្រូវតាមថ្នាក់?
ពាក្យណាខ្លះដែលជាវេវចនៈនឹងគ្នា ?

១០៤- ការហាត់

១០៥. សត្វពាននរមើលទោសខ្លួនឃើញឬទេ? តើ
ពាននរពេញចិត្តនឹងអត្តភាពរបស់ខ្លួនឬទេ? ពាក្យត្រង់ណាខ្លះ
ដែលសឲ្យឃើញថាស្វាពេញចិត្តនឹងខ្លួន? ចូរស្រង់?

១០៦- អក្ខរាវិរុទ្ធ

ពានរ (រ មកពី ;នរ ក> ពា) ។ ឥស្សូរ (រ) ។

សមរម្យ (ម្យ)

១០៧- សរសេរតាមសូត្រ ព្រះឥស្សរឹជំពាធរ

១០៨- តែងៈសបក្តី

អ្នកបានចិញ្ចឹមសត្វណាមួយ ចូរអ្នកពិពណ៌នាអំពីសត្វនោះអំពីគុណសម្បត្តិ និងគុណវិបត្តិ អំពីផលដែលសត្វនោះផ្តល់ឲ្យ ។

## មេរៀនទី១៩

# វិសេសនសព្ទនាម

## វិសេសនសព្ទនាមនិយម វិសេសនសព្ទនាមអនិយម



១– មួកនេះល្អហើយ សមផង

២– មួកខ្លះមិនសមហើយ មិនល្អទៀត

### ពិនិត្យ

១– ពាក្យថានេះ ក្នុងឃ្លាទី១ បញ្ជាក់ឲ្យឃើញថា មួកដែលគេចង្អុលប្រាប់មិនមែនជាមួកក្រៅឯណាទៀតទេ ។ ពាក្យដែលគេសំគាល់ចង្អុលបញ្ជាក់ដូច្នេះ ហៅថា វិសេស

នៈសព្ទនាមនិយម គឺសព្ទនាម សំដៅសេចក្ដីទៀង ទាត់ ហើយដាច់ទៅលើនាមតែមួយ ៗ

២- ក្នុងឃ្លាទី២ ពាក្យថាខ្លះ ជាពាក្យសំដៅសេចក្ដីមិនដាច់ស្រេចមិនថាជាវត្ថុណាមួយ ដូចឧទាហរណ៍ថា មួកខ្លះ មិនដឹងជាមួកមួយណា មិនដាច់ស្រេចថាជារបស់នរណា ឬនៅឯណា ពាក្យដូច្នេះ ហៅថាវិសេសនៈសព្ទនាម អនិយម គឺសំដៅសេចក្ដីមិនដាច់ស្រេច

**សង្ខេប**

| | |
|---|---|
| នេះ | វិសេសនសព្ទនាមនិយម ឯកវចនៈ បទវិសេសន៍របស់មួក |
| ខ្លះ | វិសេសន៍សព្ទនាមអនិយម ឯកវចនៈ បទវិសេសន៍របស់មួក |

បំណាំ វិសេសនសព្ទនាមទាំង២ ត្រូវសម្ពន្ធ ចូលទៅក្នុងនាម ត្រូវមានវចនលិង្គដូចនាមដែរ ៗ

## មេរៀន

ពាក្យសំរាប់ប្រើជំនួយនាមនាម មានលំនាំជាបទវិសេសន៍ ដើម្បីនឹងមិនឲ្យប្រឡំសេចក្ដីក្នុងសង្កាត់ប្រយោគនិមួយ ៗ ហៅថា វិសេសនសព្វនាម ។

វិសេសនសព្វនាម ចែកជា ២ យ៉ាងគឺ វិសេសនសព្វនាមនិយម នឹងវិសេសនសព្វនាមអនិយម ។

១- វិសេសនសព្វនាមនិយម វិសេសនសព្វនាមដែលសំដែងសេចក្ដីទៀងទាត់ហើយដាច់ស្រេច

ឧ.... ប៉ុន្តែចប់ក្រែងជូនខ្សែអន្ទាក់នោះ ទៅជាក្រដាប់ក្រប៉ើក ហើយស្រាប់តែលេបព្រាននោះមកដល់ជើង ខ្ទង់

អញជាអណ្ដើកមុខជានឹងស្លាប់ ក្នុងកណ្ដាប់ដៃព្រាននេះមិនខានឡើយ (សោម-ឡុច)

២ - វិសេសនសព្វនាមអនិយម : វិសេសនសព្វនាម ដែលសំដែងសេចក្ដីមិនទៀងទាត់មិនទាន់

មេរៀន(ត)

ស្រប ។

ឧ- តែក្នុងសម័យបច្ចុប្បន្ននេះ ពួកអ្នករៀនខ្លះក៏បាន

ទៅនៅវត្តពីក្មេង ក៏មានអ្នកខ្លះឪពុកម្ដាយនាំយកទៅឲ្យរៀន

(ខកញ៉ាមមហាមន្ត្រី ញ៉ឹក-នូវ (ច្បាប់ក្រមបរិយាយ)

| វិសេសនសព្វនាម | |
|---|---|
| និយម | អនិយម |
| នោះនុះ;ហ្នឹង, នេះ , ម្នាក់.ឯណោះ,ឯណោះ | ខ្លះ; អ្នកខ្លះ, ពួកខ្លះ , ផ្សេង; ដទៃ, ទាំងពួង ទាំងអស់, ឯទៀត |

ចំណាំ: វិសេសនសព្វនាម មានលំនាំទំនងប្រហែល

គ្នានឹងគុណនាមដែរ ។

វេយ្យាករណ៍ ភក្យស័ព្ទ

សំនួរ

១០៩ – ដូចម្ដេចដែលហៅថាវិសេសនសព្វនាម ? មាន

ប៉ុន្មាន ? មួយ ៗ មានន័យខុសគ្នាដូចម្ដេច ? វិសេសន
សព្វនាមមានមុខងារដូចគុណនាមឬទេ ?

ការហាត់

១១០ - ចូរធ្វើឃ្លាជាមួយនឹងវិសេសនសព្វនាមខាងក្រោម
នេះ ហ្នឹង, ម្នាក់, នុះ, នោះ, ទាំងពួង, ដទៃ,
ឯទៀត

អត្ថបទ ត្រូវធ្វើផ្ទះតាមអនាម័យឲ្យប្រ
សើរឡើង

នៅប្រទេសខ្មែរយើងនៅស្រុកស្រែចំការ យើងប្រទះ
ឃើញផ្ទះខ្លះធ្វើអំពីបាយអនាម័យប្រក់ស្លឹក ៗ ផ្ទះទាំង
អស់សង់មិនសូវបានល្អទេ ។ ដើម្បីនឹងធ្វើឲ្យជាផ្ទះអនា
ម័យបាន គេត្រូវចោះបង្អួចទ្វារឲ្យច្រើនហើយធំល្មមនឹងខ្យល់
ចេញចូលស្រួល ។ ត្រូវប្រើទឹកកំបោរលាបជញ្ជាំងមួយឆ្នាំ
ពីរដង ប្រយោជន៍នឹងបំផ្លាញអតិសុខុមប្រាណ ។ បើ

កាលណាមានធ្វើពិតានមួយ ផ្ទះនោះនឹងបានត្រជាក់ស្រួល ហើយធូលីមិនធ្លាក់ចុះពីដំបូលមកលើគ្រឿងតុបតាំងបាន-ឡើយ ។ ..... ។ ជុំវិញផ្ទះត្រូវឲ្យស្អាតដែរ ។ បសុសត្វក្ដីទិញ្ចាប្ដុសត្វពាហនៈមិនត្រូវឲ្យនៅជាប់នឹងផ្ទះម្ចាស់ទេ ។

ពាងក្រឡដែលនៅជុំវិញផ្ទះឬថ្លុកបង្អូរទាំងពួង ត្រូវគ្របឲ្យជិត ឬលុបដីឲ្យស្មើប្រយោជន៍កុំឲ្យមូសកើតបាន ។

(ស្រង់ពីមូលដ្ឋានខេមរភាសា)

សំនួរ

១១១-ចូរស្រង់យកវិសេសនសព្ទនាមទាំង២ដែលមានក្នុងអត្ថបទនេះ ? ចូរសម្ពន្ធវិសេសនសព្ទនាមទាំងនោះមកផង?

ការហាត់

១១២-ចូររកស័ព្ទដែលសរសេរជា ៣ ហើយអានជា ៤ ដូចពិតាន ? សត្វដូចម្ដេច ដែលហៅថាសត្វពាហនៈ ? ចូររាប់មកខ្លះ ? ចូររកវេវចនៈស័ព្ទនឹងពាក្យថា „ផ្ទះ„ ,

១១៣ អក្ខរាវិរុទ្ធ

លាប. (កិ.សរសេរប្រកបនឹង ប បើនាមប្រកបនឹង ក ) ។ ពិតាន (សរសេរជាតាន ម.ថ.ជាន)

១១៥ សរសេរតាមសូត្រ (គ្រូយកអត្ថបទខាងលើនេះ)

១១៦ តែងសេចក្ដី

ថ្ងៃឈប់រៀន អ្នកបានដើរកំសាន្តចិត្តលេង អ្នកបានឃើញគេកំពុងរៀបសង់ផ្ទះ ចូរអ្នកនិយាយអំពីមុខងារនៃជាងម្នាក់ ៗ ដែលកំពុងរៀបសង់ផ្ទះ ចូរអ្នកនិយាយអំពីមុខងារនៃម្នាក់ ៗ ដែលកំពុងធ្វើការ ហើយនឹងឧបករណ៍ដែលជាងនេះប្រើប្រាស ។ (ត្រូវនិយាយតាមដែលអ្នកឃើញទីក្រុង ឬ ស្រុកស្រែ )

## កិរិយាវិសេសន៍    មេរៀនទី ១៦



១-ឆ្កែព្រុស    ២-ឆ្កែព្រុសខ្លាំង

### ពិនិត្យ

១-ប្រយោគថាឆ្កែព្រុស ពាក្យព្រុសនេះជាកិរិយា ដែលសុនខធ្វើតាមធម្មតា បើថាព្រុសក៏ព្រុសធម្មតា ពាក្យថា ព្រុសនេះជាកិរិយាសព្ទ

២-ប្រយោគថា ឆ្កែព្រុសខ្លាំង ពាក្យថាខ្លាំងនេះ ជាពាក្យសំរាប់បំពេញកិរិយាសព្ទ ព្រុស ឲ្យរឹតតែវិសេស ទៅទៀតពាក្យដែលឲ្យសំរាប់ជួយ បន្ថែមកិរិយាសព្ទដូច្នេះ ហៅថាកិរិយាវិសេសន៍

## សម្គុ

ខ្លាំង | កិរិយាវិសេសន៍ បំពេញកិរិយាព្រុស

ចំណាំ ស័ព្ទថាខ្លាំងនេះ បើនៅពេលម្នាក់ឯង

ជាបទគុណ បើនៅបន្ទាប់កិរិយា ហៅថាកិរិយាវិសេសន៍

## មេរៀន

កិរិយាវិសេសន៍ ជាពាក្យសំរាប់បន្ថែមកិរិយាឲ្យ
ប្លែកជាងកិរិយាធម្មតា ។

ឧ. កុមារនេះ យំខ្លាំង ។

ពាក្យខ្លះសំរាប់បន្ថែមកិរិយាគឺ ឆាប់, លឿន, ក្លាម, ក្លែត
បណ្ដាប់ . . . . ។

វេយ្យាករណ៍ វាក្យស័ព្ទ

សំនួរ

១១៧-ដូចម្ដេចដែលហៅថា កិរិយាវិសេសន៍? កិរិ-
យាវិសេសន៍និងកិរិយាខុសគ្នាដូចម្ដេច? ចូររកពាក្យដែល
ដាក់បន្ថែមឲ្យទៅជាកិរិយាវិសេសន៍ខ្លះ?

ការហាត់

១១៨-ចូររកកិរិយាវិសេសន៍ មកដាក់ជាមួយកិរិយាខាងក្រោមនេះ ដើរ, រត់, ដេក, យំ, វាយ, កាប់, ចាក់

## អត្ថបទ ព្រានសន្ទូច

មានព្រានសន្ទូចម្នាក់ ថ្ងៃមួយនាំកូនទៅស្ទូចត្រីនៅមាត់ស្ទឹងមួយ លុះស្ទូចទៅសន្ទូចធ្លាក់ទៅពន្លជាប់នឹងដង្គត់ឈើក្នុងទឹក ។ ចៅព្រានខំរាត់ទាញយ៉ាងខ្លាំង លុះរាត់ទាញមិនរួចក៏ស្មានថា ប្រហែលជាជាប់ត្រីធំហើយ ទើបប្រាប់ទៅកូនថា យើងមានលាភ បានត្រីធំហើយ បើដូច្នេះចូរកូនឯងទៅប្រាប់ម៉ែឯងឯផ្ទះថា យើងបានត្រីធំណាស់ ឲ្យម៉ែឯងដើរបង្កហេតុជំលោះនឹងបងប្អូនឲ្យពេញទាំងភូមិទៅ ។

ម្ដាយបានឮដូច្នោះហើយ ក៏ដើរបង្កជំលោះតាមបណ្ដាំប្ដីពេញទាំងភូមិ ។ ញាតិមិត្រ បានឮមេនោះដេរប្រទេចដូច្នោះ

អត់មិនបានក៏ដេរតបទៅវិញ ម្ល៉ោះហើយជំលោះនោះក៏កាន់តែផាលព៉ាលឡើង ៗ

ថ្ងៃនឹងចៅព្រានជាប្ដី កាលមុជក្បាលទៅក្នុងទឹក បានទៅប៉ះប៉ុងនឹងជង្គង់ បែកក្អែកមានទុក្ខវេទនាជាពន់ពេក ៗ ព្រាននេះ ខំងើបឡើងមកលើគោកវិញរកខោអាវមិនឃើញពីព្រោះខ្យល់បក់កួចយកទៅ ៗ

បុរសប្ដីប្រពន្ធបានទុក្ខវេទនា ដោយប៉ះទង្គិចនឹងជង្គង់នឹងចោរខ្យល់បក់យកអាវ ឯប្រពន្ធត្រូវគេលក់ថ្លៃ ៗ ជនទាំងពីរក៏បានក្ដីវិនាសទាំងពីរនាក់ ៗ

សំនួរ

សំរួលពីគតិលោក

១១៨ ចូរស្រង់យកកិរិយាវិសេសន៍ ដែលមាននៅក្នុងអត្ថ-បទខាងលើនេះ តើកិរិយាវិសេសន៍នោះ ត្រូវរួមបូលនឹងកិរិយាណាចូរប្រាប់ ?

ការហាត់

១១៩- ធំណាស់ ជាគុណនាមដូចម្ដេច? ចូរធ្វើពាក្យ

ថា «ធំណាស់» ឲ្យទៅជាបកតិគុណនាម? ចូរពន្យល់ពាក្យ

ថាស្អូបត្រីនឹងស្អូបផ្ទះតើខុសគ្នាដូចម្តេច ?

១២០ អក្ខរាវិរុទ្ធ

ណាត (ន) (ប្រកបនឹងក) ។ ៈដរ (រ) ។ រ៉ារ

(កិ) (មានរ)ជាបុ. (គ្មានរ) ។

១២១–សរសេរតាមសូត្រ ព្រានសន្ទូច

តែងសេចក្តី

១២២–ចូរអ្នកអធិប្បាយអំពីការនេសាទត្រី នៅវេលា

ឈប់រៀនតើអ្នកចាប់អារម្មណ៍ដូចម្តេច ដល់អ្នកចូលទៅ

សិក្សាវិញ ?

# មេរៀនទី១៧

## សំខ្យាសព្ទ

### បកតិសំខ្យា បូរណសំខ្យា



១- កុមារ បួន នាក់ មានអាយុស្មើគា

២- កុមារ ពីរនាក់ស្លៀកខោខ្លី ៦ ទីបី ទីបួន ឈរមើលគេលេង ។

——— ពិនិត្យ ———

១- ពួកកុមារទាំងឡាយនេះ មានអាយុស្មើគ្នា ។ យើងរាប់ មួយ ពីរ បី បួន ហៅថាសំខ្យាសព្ទ ក្មេងទាំងអស់បួននាក់ ។ ពាក្យថាបួននេះ ជាពាក្យសំរាប់រាប់ឲ្យដឹង

ចំនួនថាប៉ុណ្ណោះប៉ុណ្ណោះ ដូចប្រយោគទី១ ថា ក្មេងបួននាក់ បួននេះហៅថា បកតិសំខ្យាស័ព្ទ ។

២– ពាក្យដែលសំរាប់ឲ្យដឹង ជួរ ថ្នាក់ ជាន់ ដូចពាក្យថា ទីបី នឹង ទីបួន ដែលសំរាប់ប្រាប់ជួរឬថ្នាក់ កុមារទីបី នឹងទីបួនហៅថា បូរណសំខ្យាស័ព្ទ

សម្ពន្ធ

| | |
|---|---|
| បួន | បកតិសំខ្យា ឯកវចនៈ បុល្លិង្គ បទវិសេសន៍កុមារ |
| ពីរ | បកតិសំខ្យា ឯក- បុំ- បទវិសេសន៍កុមារ |
| ទីបី | បូរណសំខ្យា ឯក- បុំ- បទវិសេសន៍កុមារ |

ចំណាំ: សំខ្យាស័ព្ទ ត្រូវជាបទវិសេសន៍របស់នាម ត្រូវមានលិង្គវចនៈ ទៅតាមនាម ។

មេរៀន

សំខ្យាស័ព្ទ : គឺជាស័ព្ទសំរាប់រាប់ចំនួនរបស់នាម។

មេរៀន (គ)

សំខ្យាស័ព្ទ ចែកទៅជា ២ យ៉ាងគឺ បកតិសំខ្យា ១ បូរណសំខ្យា ១ ។

បកតិសំខ្យា : សំខ្យាដែលរាប់ចំនួនតាមប្រក្រតី ឡើងដ៏តែចំនួន

ឧ– កុដិថ្នាក់រៀន មានកូនសិស្ស ៣៥នាក់

បូរណសំខ្យា: សំខ្យាដែលសំរាប់រាប់ឡើងតាមលំដាប់ថ្នាក់ លំដាប់ជាន់ .....

ឧ– ប្អូនខ្ញុំរៀននៅថ្នាក់ទី ៦ ទំនើបជាតិ

ពាក្យដែលសំរាប់ប្រើនឹងបូរណសំខ្យានោះគឺ: ទី... ដំបូង. . .

ចំណាំ ១– បើលេខផ្ទះវថយន្តជាដើម គេមិនធ្លាប់ដាក់ពាក្យថា „ទី„ ទេព្រោះគេមិនអាចប្រឡំបាន ប៉ុន្តែមានន័យដូចបូរណសំខ្យា

ឧ– ផ្ទះលេខ ៥៤ វិថីព្រះអង្គឌួង (គឺផ្ទះទី៥៤..)

មេរៀន(ត)

២-គន្ធកាសាបាលី គេមានបច្ច័យសំរាប់ឲ្យស្គាល់ទី

ខ-បឋមា (ឥ.) បឋមោ (បុ) ទុតិយា.....

វេយ្យាករណ៍ ពាក្យស័ព្ទ

សំនួរ

១២៣- ចូរឲ្យអត្ថន័យសំខ្យាស័ព្ទ? សំខ្យាស័ព្ទមានប៉ុន្មាន? បកតិសំខ្យា និងបូរណសំខ្យាខុសគ្នាដូចម្តេច?

ការបោត់

១២៤-ចូរធ្វើឃ្លានឹងសំខ្យាស័ព្ទខាងក្រោមនេះ

ទី១-ដំបូង-ម្នាក់, ២៥- ទី ៥-ទុតិយ, បញ្ចមី ។

អត្ថបទ ក្រុងអង្គរ

កាលគង់កំឡុងសតវត្សរ៍ ទី ៩ និងទី១៣នៃគ្រិស្តរាជ ក្រុងកម្ពុជា ជាដែនមួយគបដោយប្តូនុភាពខ្លាំងណាស់ ។ ខេមរជាតិជាន់នោះ បានកសាងសេនាសនៈដ៏ល្អៗគួរស្ងើចៗ

ក្រោយមកខ្មែរៗ បែកខ្ញែកពួនគ្នាទៅ បែកកម្ពុជាខាងត្បូង ដោយទ័ពសៀមលុកលុយ ជាន់យកក្រុងអង្គរ គុហាសនៈដ៏ប្រសើរទាំងនោះ ក៏បោះបង់ចោល ជាកន្ទួងដែលព្រៃទន្ទ្រានលុបទៅ អ្នកប្រទេសអឺរ៉ុបទើបបានឃើញថ្វីដៃអស្ចារ្យនៃខ្មែរដែលរលត់បាត់មកជាយូរអង្វែងហើយដោយវត្ថុនោះ ។

លុះដល់មកដល់ គ.ស.១៩០៧ ក្រុងទេពបានបង្វែរអង្គរមកក្រុងកម្ពុជាវិញ ទើបរកការឲ្យកាប់ត្រាយព្រៃដែលរួបរឹតប្រាសាទដ៏ធំៗខ្លះបានលេចចេញរូបរាងប៉ុណ្ណឹងឡើងៗ

ប-ឈុំ

សំនួរ

១២៥–ប្អូនស្រង់យកសំខ្យាស័ព្ទដែលមាននៅក្នុងអត្ថបទនេះ ? ហើយឲ្យឈ្មោះមកផង ? អង្គរដែលបានវិលប្អូលមកប្រទេសកម្ពុជាវិញ នៅគ្រិស្តសករាជប៉ុន្មាន ? បើ

រាប់ជាសតវត្សរ៍ តើក្នុងសតវត្សរ៍ទីប៉ុន្មាន ?

១២៦- អក្ខរាវិរុទ្ធ

គុហាសនៈ=គុហា+អាសនៈ ។ បង្អើរ (រ) ។ អង្គុរ(រ)

ទេព ម.ប.ថេប ។

១២៧- សរសេរតាមសូត្រ ក្រាដ៏អង្គុរ

១២៨ តែងសេចក្ដី

ចូរអ្នកនិយាយអំពីបូជនីយវត្ថុមួយ ដែលអ្នកបានឃើញ តើគេធ្វើឡើងជានិមិត្តរូបដូចម្ដេច ? សករាជណា ? ក្នុងរាជ្យណា ? ។

# មេរៀនទី ១៨

## អាលបនៈ



ម្នាល កូន ! ត្រូវខំសិក្សាឲ្យមែនទែន ទាន់ខ្លួននៅ-ក្នុងបឋមវ័យ ,

## ពិនិត្យ

ម្ដាយឲ្យដំបូន្មានកូនថា ម្នាលកូន . . . ។ ពាក្យថា ម្នាលនេះ ជាពាក្យសំរាប់អ្នកធំ ហៅពួកតូច ពាក្យនេះមានន័យថាស្រែកហៅ កាលបើចេញពាក្យថាម្នាលដូច្នេះអ្នក-ដែលគេហៅនោះ មុខតែប្រុងខ្លួនចាំស្ដាប់មិនខាន ពាក្យ-

ដែលពោលទៅដូច្នេះ ហៅថា អាលបនៈ ។ ឯអា-
លបនៈនេះ ត្រូវប្រើទៅតាមមនុស្សទាបខ្ពស់ ។

## សម្ពន្ធ

| | |
|---|---|
| ម្នាល | អគារវលបនៈ ឯកវចន |

## មេរៀន

អាលបនៈ ជាពាក្យសំរាប់ហៅឬពោលចំពោះនរណាមួយ ៗ អាលបនៈមាន ២ យ៉ាង គឺ សគារវលបនៈ និងអគារវលបនៈ.

សគារវាលបនៈ គឺអាលបនៈសំរាប់និយាយដោយគោរពចំពោះបុគ្គលជាន់ខ្ពស់

ឧ- បពិត្រព្រះអង្គ ! ...

អគារវាលបនៈ ជាអាលបនៈសំរាប់ហៅមនុស្សជាន់ទាប

ឧ- ម្នាលកូន ! ...

មេរៀន (គ)

ពាក្យសំរាប់ប្រើគឺៈ

សគារវាលបនៈ បពិត្រ . .

អគារវាលបនៈ ម្នាល, នែ, ហៃ, . .

វេយ្យាករណ៍ ភាក្យសព្ទ

សំនួរ

១២៩ ដូចម្ដេចដែលហៅថាអាលបនៈ? មានប៉ុន្មានយ៉ាង ?

សគារវាលបនៈសំរាប់និយាយចំពោះបុគ្គលបែបណា ?

ការហាត់

១៣០-ចូរបំពេញឃ្លាខាងក្រោមនេះ

. . . .ព្រះអង្គ ! ។ . . . កូន ! . ។ . . . ចា !

. . . .ភិក្ខុ ! ។ . . សភាមណោរ ! ។ . . មហាថេរ ! ។

អត្ថបទ

## រឿងកូនចៀមនិងឆ្កែព្រៃ

មានកូនចៀម ១ ចុះទៅផឹកទឹកជ្រោះ កាលនោះមាន

ឆ្កែព្រៃ ១ ចុះទៅផង បានឃើញកូនចៀមនោះហើយ កើត

គូបចង់ចាប់ស៊ី តែឆ្កែនោះគិតថាការនឹងកំហែងចាប់ស៊ីតែ.

មុនទៅក៏បានដែរ ប៉ុន្តែហាក់ដូចជាមិនអស្ចារ្យ ចាំគេ ទោសវាឲ្យឃើញសិន គិតហើយឆ្កែព្រៃស្រដីកំហែងទៅ ថា អើយ អាកូនសត្វនេះ ម្តេចឯងក៏ចិត្តខូចម្ល៉េះគួរប្តូមកកូរ ទឹកឲ្យល្អក់ដូច្នេះ រកតែយើងផឹកផងពុំបាន ។

ឯកូនចៀមឮឆ្កែព្រៃស្តីចាប់ទោសដូច្នោះ ក៏តបថា បពិត្រលោក ខ្ញុំបាទទទួលទានទឹកនៅក្រោមលោកទេតើ ទឹកល្អក់ឯណាដែលហូរច្រាសទៅខាងលើវិញនោះ លោកនៅខាងលើខ្ញុំបាទយ៉ាងនេះ ។

ឆ្កែព្រៃតាល់ប្រាជ្ញ ទើបរកចាប់ទោសឯទៀតវិញ ក្លែងពោលថា អំពីឆ្នាំទៅមុញអាឯងដើរនិយាយដើមអញៗ តែគេទេតើ បពិត្រលោក រូបខ្ញុំបាទនេះ មិនទាន់ទាំង. កើតផង បើជាកើតសោតក៏នៅពុំទាន់ចេះនិយាយផង ហេតុដូចម្តេចក៏លោកថាខ្ញុំបាទ និយាយដើមលោកពីឆ្នាំទៅ

មិញនោះ ឆ្កែព្រៃពាល ប្រាថ្នារកចាប់ទោសកូនចៀមមិន-បានក៏លោតទៅចាប់កូនចៀមស៊ីទាំងរស់ ៗ

(គតិលោក)

សំនួរ

១៣១-ចូរស្រង់អាលបនៈសព្ទដែលមាននៅក្នុងអត្ថបទនេះ ? ពាក្យថា បពិត្រលោក ជាអាលបនៈដូចម្ដេច? សំរាប់ប្រើទៅនឹងជនដូចម្ដេច ?

ការហាត់

១៣២-ក្នុងអត្ថបទនេះ អ្នកអាចទាញយកគតិដូចម្ដេច? ចុះសំដីដែលកូនចៀមនិយាយថា ទឹកល្អក់មិនដែលហូរ-ទៅលើ តើត្រូវឬខុស ?

១៣៣ អក្ខរាវិរុទ្ធ

គល (មិនឲ្យបន្ទុក) ៗ កូរ (រ) បពិត្រ (ត្រ) ៗ

១៣៤–សរសេរតាមសូត្រ រឿងកូនចៀមនិងឆ្កែព្រៃ

១៣៥ តែងសេចក្ដី

ចូរអ្នកអធិប្បាយអំពីបក្សីនៅក្នុងសួនអ្នក នៅពេល–ដែលអ្នកបាចស្រូវឲ្យស៊ី តើសត្វសប្បាយដូចម្ដេច ? សត្វ-មានអំណាចដេញសត្វតូចៗកុំឲ្យចូលមកស៊ីដូចម្ដេច ?

# ឧទានស័ព្ទ មេរៀនទី១៩




ចោរ! ចោរ! ស្លាប់ហើយ!

ចាប់! ចាប់! លួចអស់!

## ពិនិត្យ

ពាក្យដែលបន្លឺឡើងដាច់ៗប្លែកពីធម្មតា ហើយ ពាក្យទាំងនេះត្រូវមានសញ្ញានេះ (!) ជាសំគាល់ ។ សញ្ញានេះសោតមានន័យ៣យ៉ាង កាលបើព្រួយចិត្តសញ្ញា

នេះហៅថា សំវេគសញ្ញា ឧទានស័ព្ទត្រូវធ្វើឲ្យមានចិត្តសង្វេគ ៗ បើមានសេចក្ដីអស្ចារ្យអ្វីមួយ ហៅថា អច្ឆរិយសញ្ញា ឧទានស័ព្ទ ត្រូវបន្លឺឡើងឲ្យមានសេចក្ដីដូចជាភ្ញាក់ភ្ញាក់ ៗ បើឲ្យពរជោគជ័យ ត្រូវហៅថា ឧទានសញ្ញា ត្រូវបន្លឺដោយសេចក្ដីរីករាយទៅកេ ដូចជា ជយោ! សាធុ! ។ល។

## សម្ពន្ធ

| | |
|---|---|
| ស្លាប់ហើយ ! | ឧទានស័ព្ទ បានសេចក្ដីទុក្ខ |

ចំណាំ ឧទានស័ព្ទគ្មានសម្ពន្ធបទណាទេ ត្រូវថាត្រឹមតែស័ព្ទមួយប៉ុណ្ណោះ

## មេរៀន

ឧទានសព្ទ គឺជាស័ព្ទសំដែងប្រាប់នូវសំឡេង ដែលខុសពីសំឡេងធម្មតា

## មេរៀន (ត)

ឧ- ជូន ! ជាំន !

ឧទានស័ព្ទនេះត្រូវប្រើសព្ទនេះ ( ! ) ដែលមានអត្ថន័យ ៣ យ៉ាងគឺ:

១-បើកើតទុក្ខព្រួយ អាណិតអាសូរ ហៅថា សង្វេគសញ្ញា

ឧ-ស្លាប់ហើយ ! ជួយ ! ( សង្វេគសញ្ញា )

២-បើឃើញអស្ចារ្យដោយភ្ញាក់ ឬស្រាប់តែភ្ញាក់ព្រើត ហៅ អច្ឆរិយសញ្ញា

ឧ-ពូកែមែន !

៣-បើជូនពរសព្ទសាធុការ ឬស្រែកហៅ ត្រូវហៅថា ឧទានសព្ទវិញ

ឧ ជយោ ! សុខោ !

វេយ្យាករណ៍ វាក្យស័ព្ទ

សំនួរ

១៣៦-ឧទានស័ព្ទ មានន័យដូចម្ដេច ? ចូរពន្យល់ពាក្យថា (ព្ទូកមែន! និង (កូនអេះព្ទូកមែន) ខុសគ្នាយ៉ាងណា ?

ការហាត់

១៣៩· ចូរឲ្យឈ្មោះពាក្យខាងក្រោមនេះទៅតាមសព្ទទាំង ៣ ឧអាណកិតពេក! ប្រសប់មែន! ក្លាហានមែនដូយ! ស្លាប់ហើយ! អែយ៉ូយ! ចុល!

ឧទាហរណ៍ ឧអាណកិតពេក (សំវេគសញ្ញា)

អត្ថបទ អារុំធគ្រោះនៅជើងភ្នំកងវ៉ាំ

ឆាំង! ឆាំង! ឆាំង! ប្រ៉ុស! ប្រ៉ុស! ដូចឧទេនរាជទប់កម្លាំងអាវុធរបស់ណាប្រុទ្ធមិនបាន ក៏ថយផុតគ័នរូសវែដលគេគួរសំគាល់. . .

សូមចៅប្រយ័ត្នស្ទៀតក្រោមឲ្យមែនទែន (សំដីតាឆាន់) ផុតវាចារបស់តាឆាន់ស្ទើរមិនទាន់ ឧទេនរាជសុះបុក

ជាវណ្ណបុទ្ធិទាំង ! ទាំង ! មុខអាវុធទ្រង់ជួបគ្នានឹងអាវុធវណ្ណបុទ្ធិបង្កើតជាព្រាយផ្កាភ្លើងខ្ជាតៗដូចបុគ្គលដំបំពង់ប៉ុយៗ

. . . . . . . . . . .

. . . . . . . . . . .

ទ្រង់ទទេននឹងបានព្រឹស្នាដៃរបស់គ្រាក់កំទៅដែរ ថ្វីត្បិតតែទ្រង់មានព្រះកាយពលទៀយខ្លាំងៗ ទ្រង់បានប្រឹងខ្លួនហើយជាស្រេចឲ្យតែគ្រាក់ភ្ញាក់ស្មៀត ព្រះអង្គនឹងបំផ្លានជាវគ្រាក់ឲ្យសូរវុត ! !

(ចេះតិបពង្សន ព្រះសូរ្យរាជា)

សំនួរ

១៣៨-ចូរស្រង់យកឧទានស័ព្ទ ហើយបញ្ជាក់ប្រាប់ឲ្យឃើញ-ច្បាស់នៃការប្រើសព្ទ ដូចឧទាហរណ៍

ទាំង ! អច្ឆរិយសញ្ញា (        )

ការហាត់

១៣៩-តាមក្បួនវេយ្យាករណ៍ គំនូស ជាបទអ្វី? ចូរធ្វើប្រយោគកម្មវាចក(គំនូសដែលគេគូសសំគាល់ .....)

ឲ្យទៅជាប្រយោគកត្តុវាចក ?

តែងសេចក្ដី

១៤០–ចូរអ្នកអធិប្បាយអំពីហេតុអ្វីមួយដែលអ្នកគួរកត់ត្រាទុកក្នុងចិត្ត នោះជាហេតុនោះអស្ចារ្យក្ដី គួរឲ្យសំវេគក្ដី ។ តើហេតុនោះអ្នកគួរយកតម្រាប់ឬលះចោលព្រោះហេតុអ្វី ?

# បរិវារសព្ទ  មេរៀនទី២០




បុរសពីរនាក់នេះល្អល្អាច់ណាស់ ធំណាស់ប៉ុណ្ណោះ ហើយមិនទាន់មានផ្ទះសម្បែងផង!

——————— ពិនិត្យ ———————

ក្នុងឃ្លាខាងលើនេះ មានពាក្យថា ល្អល្អាច់ និង(ផ្ទះសម្បែង) ពាក្យថា ល្អាច់ ជាពាក្យសំរាប់ឲ្យជួយបង្ហើយសព្ទខាងដើមសព្ទខ្លួន ដើម្បីជួយលើកសួយសព្ទនោះឲ្យរឹងរឹតតែមានន័យទូលំទូលាយឡើង ហើយឲ្យពីរោះទៀតផង

បើតាមពិនិត្យមើលទៅភាសាខ្មែរយើងច្រើនតែនិយាយ - ផ្ទួនៗ ដូចជាពពោយនាយថា ទំក្រួចហ្ន៎! ទំក្រួច! ដូច្នេះជាដើម ព្រោះហេតុនោះពាក្យថាល្អាប់ ទឹងសម្លែងហៅថា បរិភាសស័ព្ទ

## មេរៀន

បរិភាសស័ព្ទ គឺជាស័ព្ទសំរាប់ជួយបន្ថែមពាក្យដែល ជានាម កិរិយា ទឹងគុណនាមឲ្យពីរោះ ហើយទឹងឲ្យមាន ន័យទូលំទូលាយ ។- គេតែងតែយកនំនែកបេកអំពៅទឹង អំបុក បន្ថែមឲ្យក្មេងក្មានតាមទំលាប់ពីដើមមក-

(តិម.សែត)

វេយ្យាករណ៍ វាក្យស័ព្ទ

សំនួរ

១៤១- បរិភាសស័ព្ទមានន័យដូចម្តេច? គេប្រើជាមួយនឹង ពាក្យដូចម្តេចខ្លះ? ចូរឲ្យឧទាហរណ៍?

ការហាត់

១៤២–ចូររកពាក្យជាបរិវារស័ព្ទដែលត្រូវយកមកផ្សំជាមួយពាក្យទាំងនេះ

កូន, ចោរ, បាន, ផ្ទះ, គោ, ចំណី, ស្មៅ . . .

អត្ថបទ  បុណ្យចូលឆ្នាំចិន

. . . . ឯទីផ្សារផ្សេក នៅគ្រប់វិថីមានលក់ផ្លែក្រូចទន្លាប់ មៀនបេកឪឡឹកតរដូចជាដំបូកបម្រុះពណ៌ផ្សេងៗគ្នា ។ ក្រៅពីផលាទុំទាំងនេះ មានមនុស្សម្នាចោមរោមដណ្ដើមគ្នាទិញប្រញាយ គេឃើញមានទំនៃក ដំណាប់គោក. ទឹក. ក្រៀម និងគ្រាប់ស្ករប្រកបដោយពណ៌គ្រប់យ៉ាង ។

ក្នុងវេលាចូលឆ្នាំថ្មីនេះ នៅគ្រប់ផ្ទះសម្បែងចិនយួនដែលមានក្រដាសក្រហមបិទគ្រប់សសរ គេត្រូវតែមាត់មនុស្សប្រៀងសើចក្អាកក្អាយនិងសូរបានក្លូន ទង្គិចគ្នាដោយមានការជប់លៀងភោជនាហារស្ទើរមិនដាច់ ។

ក្នុងកំណត់បីថ្ងៃ ហើយធំបំផុតនៅថ្ងៃចូលឆ្នាំដំបូងយួន បិនតមមិនហ៊ានធ្វើការអ្វីឲ្យនឿយហត់ឬនិយាយ ពាក្យអា-ក្រក់ឡើយ ៗ បើទឹងធ្វើអ្វីបន្តិចបន្តួច គេខំធ្វើដោយផ្ចិតផ្ចង់ឲ្យខាងតែបានល្អ ព្រោះគេជឿថានឿយឬអាក្រក់ពីដើមឆ្នាំទៅហើយ គេទឹងនឿយឬអាក្រក់រហូតពេញមួយឆ្នាំ ៗ ម៉្លោះហើយក្នុងបីថ្ងៃនេះ គេគិតតែស៊ីផឹកគិតលេងសប្បាយទឹងស្លៀកពាក់តែងខ្លួនស្រស់បស់មុខប្រិមប្រិយ ៗ

## មូលវិជ្ជា

សំនួរ

១៤៣ ចូរស្រង់យកបរិវារស័ព្ទដែល មានក្នុងអត្ថបទនេះ ហើយប្រាប់ថា តើពាក្យនេះត្រូវជាបរិវារនាម-កិរិយា គុណនាមណា? ចូរសម្ពន្ធពាក្យទាំងនេះ ហើយបង្អុសប្រាប់ពាក្យដែលត្រូវបរិវារគឺ ម្នា, នែក, ក្សាន, ពុក.

១៤៤ ការហាត់

បុណ្យច្រូលឆ្នាំចិនយូរនូវកំណត់ប៉ុន្មានថ្ងៃ? ថ្ងៃណាជាថ្ងៃធំជាងគេ? ព្រោះហេតុអ្វីបានជាចិនយួនគេមិនធ្វើការ ហើយនឹងនិយាយពាក្យអាស្រូវ?

១៤៥-សព្ទានុពាក្យ វិថី, ផ្លូវ, ថ្នល់, បថ, (ផលបថ) មហាវិថី, វក្រវិថី, តិរវិថី ផ្លូវលំ, ផ្លូវសួន, ផ្លូវប្រេក,

១៤៦-សរសេរតាមសូត្រ

បុណ្យច្រូលឆ្នាំចិន

១៤៧-តែងសេចក្ដី

ចូរអ្នកអធិប្បាយអំពីបុណ្យអ្វីមួយ ដែលមាននៅក្នុងស្រុកខ្មែរ បុណ្យនោះធ្វើក្នុងភូមិ នៅក្នុងវត្ត នៅក្នុងផ្ទះតាមតែអ្នកចូលចិត្តនិយាយ?

# មេរៀនទី២១

## និបាតសព្ទ




### ពិនិត្យ

ពាក្យថា ដ៏, ដោយ, ដែរ នេះ ជាសព្ទគ្មានអត្ថន័យ ជាពាក្យដាក់មកសំរាប់បំពេញ នាម, គុណនាម, កិរិយាសព្ទ ឲ្យនឹងតែមានសេចក្ដីពិរោះ ច្បាស់លាស់ទៅទៀត ។

### មេរៀន

និបាតសព្ទ ជាពាក្យសំរាប់ជំនួសនាម គុណនាម កិរិយាសព្ទ ឲ្យមានសេចក្ដីពិរោះ

មេរៀន(គ)

១- យើងអាចសង្កេតឃើញបាន ដោយសារ មនុស្ស
ប្រែបនេះ ច្រើនតែខ្ជិលច្រអូសបណ្ដោយ ៗ ជួនកាលស្មាគ្គីក៏មាន (បណ្ដាំ)

និបាតសព្ទ គឺ ក៏, ក៏ដោយ, ក៏ដែរ, ក្ដី, ផង, ឯ. បើ, ទោះ,
ទោះបើ, ពុំនោះសោត, ដែរ,

វេយ្យាករណ៍ ភាសាខ្មែរ

សំណួរ

១៤៨. ដូចម្ដេចហៅថានិបាត ? និបាតសព្ទនេះមានន័យ
ពេញគ្រប់គ្រាន់ឬទេ? ចូររកនិបាតសព្ទខ្លះដែលស្គាល់?

អត្ថបទ សេចក្ដីផ្តួសប្រហែសក្នុងការផឹក

មានអ្នកខ្លះឃើញទឹក ក៏ចេះតែផឹកក្អឹកៗ ពៅមិនប្រយ័ត្ន
ជួនកាលមានហេតុនាំឲ្យមានគ្រោះថ្នាក់ក៏សឹងមាន ដូចជនខ្លះ
ដែលចូលចិត្តផឹកទឹកគ្រូបប្រញាប់ មានជួនកាលផឹកដោយទាំង

គ្រាប់ក្របក៏មាន មានអ្នកខ្លះដកប្រញាប់ប្រញាល់ពេក ទៅជាល្អក់ក៏មាន ហេតុនេះអ្នកធ្វើតោងតែប្រុងប្រយ័ត្ន អ្នកដកតោងពិនិត្យ មើលមុនទឹងដកនោះដែរ ៗ ឯអ្នកខ្លះទៀតដាក់ឆ្អេញវិលាលេបថ្នាំ គ្រាប់ជាមួយ ទឹងទឹកមិនបាន ប្រុងប្រៀបឲ្យហ្វត់បត់ឆ្អេញដែលដាក់របួតជ្រុះបុះបួលជាមួយ គុណភាគន្ទបំពង់កក៏មាន ៗ

ហេតុនេះត្រូវបៀសវាង សេចក្តីប្រមាទក្នុង ការផឹកទឹកការស៊ី មានទំនង់ដូចជាយើងដើរទៅក្នុងព្រឹក្សា ដែលមានបន្លាច្រើន ច្រាំងយើងត្រូវតែដើរសន្សឹមៗ កុំស្រពាន់ មិនឲ្យបន្លាមុតជើងយ៉ាងណា ការស៊ីនិងការផឹកក៏ត្រូវតែប្រុងប្រយ័ត្នដូច្នោះដែរ ៗ

(ប–ពបុំ)

សំនួរ

១៤៩- ចូរស្រង់យកទំពាសព្ទក្នុងអត្ថបទខាងលើនេះ ?

ចូររកវេវចនស័ព្ទនៃពាក្យថា ស៊ី? នៃសទិសស័ព្ទ"គំ"?

២៥០ – អក្ខរាវិរុទ្ធ

ប្រយ័ត្ន ( ័ត្ន) ។ ពិនិត្យ (ត្យ) ដែរ (រ) ។ ប្រៀប (ប្រ)

១៥១– សរសេរតាមសូត្រ (យកអត្ថបទខាងលើ)

១៥២– តែងសេចក្ដី

ចូរអ្នកអធិប្បាយអំពីការ សប្បាយអំពីការជប់លៀង ក្នុងគ្រួសាររបស់អ្នក ដែលអ្នកបានជួបប្រទះជាញឹកញយ តើគេត្រូវធ្វើការជប់លៀងនោះ ដោយបានបំណង ដូចម្ដេច ?

# មេរៀនទី ២២

## វណ្ណយុត្តិ

វណ្ណយុត្តិ ជាសញ្ញាសំគាល់ប្រើលើតួព្យញ្ជនៈ ដើម្បីនឹងបំផ្លែងតួព្យញ្ជនៈឬសព្ទដើម ឲ្យមានសំឡេងប្លែកបាកលំនាំដើម ។

## វិធីប្រើវណ្ណយុត្តិ

| ឈ្មោះ | សញ្ញា | ឧទាហរណ៍ | របៀបប្រើ |
|---|---|---|---|
| បន្តក់<br>រស្សសញ្ញា | ( ់ ) | បក់, សប់<br>បាក់, សាប់ | ធ្វើស័ព្ទវែងឲ្យជាស័ព្ទខ្លីកំបុត, ប្រើលើស្រៈអឬអា ជាភាសាខ្មែរ បាលី. សំស្ក្រឹតមិនឲ្យប្រើ ។ |
| មូសិកទន្ត<br>ធ្មេញកណ្ដុរ | ( ៉ ) | ត៉ា, ស្រម៉<br>ប៉ើន, ញ៉ាំង | ប្រើលើអក្សរ ង> ង៉, ញ> ញ៉, ន> ន៉, ប> ប៉, ម> ម៉, រ> រ៉, យ> យ៉, វ> វ៉ |

| ឈ្មោះ | សញ្ញា | ឧទាហរណ៍ | របៀបប្រើ |
|---|---|---|---|
| ត្រីសព្ទ | ( ៊ ) | ហ៊េ, ហ៊ី | ប្រើនៅលើអក្សរ ប > ប៊, ស > ស៊, ហ > ហ៊, អ > អ៊, ស្រៈ ើ ឿ ៀ មិនបាច់ប្រើ ។ |
| សំយោគ | ( ័ ) | វិទ្យាល័យ | លំអៀងពាក្យបាលី និងសំស្ក្រឹតឲ្យទៅជាពាក្យខ្មែរ ឬប្រើចំពោះពាក្យណាដែលមិនប៉ះជាស្រៈ អ ឬស្រៈ អា. ។ |
| របាទ | ( ៌ ) | គក៌, ធម៌ | បំនួសរ ចំពោះតែពាក្យសំស្ក្រឹតក្លាយទៅជាពាក្យខ្មែរ ។ |
| ទណ្ឌឃាត<br>បដិសេធ | ( ៍ ) | ប្រយោជន៍<br>ពិសោធន៍ | ឃាត់តួអក្សរចុងព្យាង្គ មិន.ឲ្យឮសំឡេង |

| ឈ្មោះ | សញ្ញា | ឧទាហរណ៍ | របៀបប្រើ |
|---|---|---|---|
| អស្តា | ( ៏ ) | ក៏,ដ៏ ន៏-ហ៏ | ប្រើលើពាក្យគោលធ្វើពាក្យនោះឲ្យខ្ទរហ័សប្រើនៅលើអក្សរ ក,ដ ន,ហ ។ |
| វិសជ្ជនីយ វិសគ្គ: រះមុខ | (ះ) | បំពោះ ពោះ សេះ | មានសំឡេងដូចតួអក្សរ(ស)ដែលជាតួប្រកបជាសំឡេងកំបុតខ្លី ។ |
| យុគលពិន្ទុ | (:) | គណ: | សំរាប់ប្រើចុចនៅចុងពាក្យបាលីឬសំស្រ្កឹតដែលមានសំឡេងកើតពីស្រៈអៈ ។ |
| កាកបាទ ជើងក្អែក | (+) | ល្អណាស់ហ្ន៎ ចា៎! | សំរាប់ទាញសំឡេងអក្សរទោលខ្លះជាប្រ- |

| ប្រភេទ | សញ្ញា | ឧទាហរណ៍ | របៀបប្រើ |
|---|---|---|---|
| លេខទោ អាមណ្ឌិត | (ៗ) | | ក្រតីដើមកន្ទួនពួនថា "បុកទឹង" ៗ សំរាប់ផ្ទួនសេចក្ដី ដែលត្រូវនិយាយ ពីរដងដែលៗផ្ទួនៗៗ |

ចំណាំ ១–យុគលពិន្ទុ (:) នឹងវិសជ្ជនីយ (ះ) ច្រើនតែប្រឡំគ្នាត្រូវធ្វើឲ្យច្បាស់ៗ ស្រឡះ(ះ) គណៈ(:)

២- បដិសេធ (៸) នឹងអស្ដា (៨) ត្រូវធ្វើឲ្យច្បាស់ អស្ដាមានលំនាំដូចលេខ១៨។. ខ្ញុំក៏ទៅដែរ; បដិសេធមានលំនាំដូចលេខ១៩។. ប្រយោជន៍ . . .

ខណ្ឌសញ្ញា ជាសញ្ញាដែលសំរាប់ញែកសេចក្ដីឲ្យមានរបៀបជាឃ្លាជាសង្កាត់ នឹងធ្វើន័យឲ្យបានច្បាស់លាស់ៗ ខណ្ឌសញ្ញាមានច្រើនណាស់ តែសព្វថ្ងៃនេះមិនមែនប្រើទាំង

អស់ទេ ដែលខ្ញុំយកមកពន្យល់នេះ បំពោះតែសញ្ញាណា ដែលប្រើជាញឹកញាប់ ។

| ឈ្មោះ | សញ្ញា | ឧទាហរណ៍ | របៀបប្រើ |
|---|---|---|---|
| ខណ្ឌ ល្បះ | ។ | .ឡើយ ។ បើ. | សំរាប់ដាក់ពីឃ្លាឬ សង្កាត់ឲ្យដាច់ស្រឡះ ដោយឡែកពីគ្នា ។ |
| ល្បះចប់ បរិយោសាន | ៕ | ជាអវសាន៕ . ហោង ៕ | សំរាប់បញ្ចប់សេចក្ដី ត្រឹមនេះ ដែលមិនមាន តទៅទៀត ។ |
| ពត់ ឃ្នាប | ( ) | ហើយថា (:២រុ ១០រុ) | សំរាប់ប្រមូលរបបទ ច្រើនឲ្យចូលនៅតែ មួយ ។ |
| វដ្ដុសញ្ញា | (–) | – នាង ។ | សំរាប់ភ្ជាប់ពាក្យគ្នា. ពាក្យហើយធ្ងន់ដើម ពាក្យ ។ |

| ឈ្មោះ | សញ្ញា | ឧទាហរណ៍ | របៀបប្រើ |
|---|---|---|---|
| ពងត្រី | (...) | ឆ្កែ.ឆ្មា.... | សំរាប់សង្ខេបពាក្យមានន័យដូច "ជាដើម" |
| បេយ្យាល | ។ល។<br>។បេ។ | ទឹកខ្មៅ។ល។ | សំរាប់បំព្រួញសេចក្ដីប្រើនឲ្យទៅខ្លីបន្តិច ។ |
| ក្បៀស | (,) | ដែរ ហើយ. | កាត់ប្រយោគឲ្យទៅជាខ្លីៗ |
| បំណុចពីរគូស | (៖) | អវយវៈ៖ | សំរាប់ដាក់ពីមុខសេចក្ដីដែលប្រុងនឹងអធិប្បាយ |
| បុច្ឆនសញ្ញា | (?) | ប៉ុន្មាន ? | ដាក់នៅចុងប្រយោគសួរ ។ |
| ឧទានសញ្ញា | (!) | គោត្ដា ! | សំរាប់បន្ទរដោយ |
| សំវេគសញ្ញា | | ឱអក់វេទនាម៉្លេះ! | ឃើញសេចក្ដីអស្ចារ្យ |
| អច្ឆរិយសញ្ញា | | ជយោ! | ស្ញប់ស្ញែង,ពេញចិត្ត |
| វិម្ហយសញ្ញា | | ល្អមែន ! | ឲ្យពរ សព្វសាធុការ |

| ឈ្មោះ | សញ្ញា | ឧទាហរណ៍ | របៀបប្រើ |
|---|---|---|---|
| | | | សេចក្តីទុកព្រួយៗ |
| វិទ្យារសញ្ញា<br>អញ្ញប្រកាសញ្ញា | « » | ."ម្នាលអានន្ទ".. | សំរាប់កំណត់ពាក្យ<br>សេចក្តីអ្នកដទៃ |
| អន្តរសញ្ញា | ('..') | ពួកគេថា(ស្អែកនេះ.) | សំរាប់បិទសេចក្តី<br>អ្នកដទៃ ដែល<br>ខ្លួនយកមកប្រើៗ |
| វង់ក្រចក<br>នខសញ្ញា | [(..)] | ព្រះហស្ត (ដៃ) | សំរាប់បិទសេចក្តី<br>ដែលមានដំណើរ<br>ដោយឡែក-សេច<br>ក្តីភាយរង ៗ |

# បកិណ្ណកសញ្ញា

| ឈ្មោះ | សញ្ញា | ឧទាហរណ៍ | របៀបប្រើ |
|---|---|---|---|
| មកពី | (<) | ធម្ម < ធមិ | ក្នុងអក្សរសាស្ត្រឲ្យថា “មកពី) ។ |
| តូចជាង | (<) | A<B | ក្នុងគណិតសាស្ត្រថា “តូចជាង) ។ |
| ទៅជា | (>) | ក+ហ > ខ | ក្នុងអក្សរសាស្ត្រថា ទៅជា) ។ |
| ធំជាង | (>) | ក > ១ | ក្នុងគណិតសាស្ត្រថា (ខធំជាងក) ។ |
| នឹង<br>ហើយនឹង | (+) | ២+៥=៨ | ក្នុងគណិតសាស្ត្រថា “បូកនឹង” ។ |
| គឺ<br>ទៅជា<br>ជា | (=) | អ×អិ=អេ | ក្នុងគណិតសាស្ត្រត្រូវថា “ស្មើនឹង” ត្រូវជា ឧ. ១០ ៖ ២=៥ |
| គុណនឹង | (×) | ២×៥=១០ | ប្រើក្នុងគណិតសាស្ត្រ ។ |

# សារបាញ


| លេខរៀង | អត្ថបទ | ទំព័រ |
|---|---|---|
| ១ | វត្តឧណ្ណាលោម | ១៣ |
| ២ | ឈាបនកិច្ច | ១៨ |
| ៣ | ដីតាខ្ញុំ | ២៣ |
| ៤ | សេចក្តីក្រោធនាំឲ្យខាត | ២៩ |
| ៥ | លាទឹកឆ្កែ | ២៣ |
| ៦ | ក្រុមញាតិខ្ញុំ | ៤៦ |
| ៧ | ការប្រឹងប្រែងអាចញ៉ាំងប្រយោជន៍ឲ្យសំរេច | ៥៤ |
| ៨ | ក្អែកញីឈ្មោលទឹកពស់ | ៦២ |
| ៩ | ត្រីមួយត្រកស្អុយមួយស្អុយទាំងអស់ | ៦៧ |
| ១០ | ទន្សាយជាប់អន្ទាក់ | ៧៤ |
| ១២ | ខ្លាឃ្មុំនឹងដើមពជ្រៃ | ៩១ |
| ១៣ | ទុងនឹងត្រី | ៩០ |
| ១៤ | ព្រះឥសូរនឹងកេនរ | ៩៨ |

| លេខរៀង | អត្ថបទ | ទំព័រ |
| --- | --- | --- |
| ១៤ | ត្រូវធ្វើផ្ទះបាយអោយគោម័យឲ្យប្រសើរឡើង | ១០៥ |
| ១៥ | ព្រានសន្ទូច | ១១០ |
| ១៦ | ចូលឆ្នាំចិន | ១៣៣ |
| ១៧ | សេចក្ដីធ្វេសប្រហែសក្នុងការផឹក | ១៣៧ |

| លេខរៀន | មេរៀន | ទំព័រ |
|---|---|---|
| ១ | វេយ្យាករណ៍ | ១ |
| ២ | អក្ខរវិធី | ១ |
| ៣ | ឃោសអឃោសៈ | ៤ |
| ៤ | សិថិលធនិត | ៥ |
| ៥ | ព្យញ្ជនបន្ថែម | ៨ |
| ៦ | ព្យាង្គ | ១០ |
| ៧ | សទិសសព្ទ វេវចនស័ព្ទ | ១៦ |
| ៨ | អត្ថានុរូប អត្ថបដិរូប | ២១ |
| ៩ | សន្ធានពាក្យ | ២៧ |
| ១០ | នាម | ៣២ |
| ១១ | លិង្គ | ៤១ |
| ១២ | វចនៈ | ៥០ |
| ១៣ | គុណនាម | ៥៨ |
| ១៤ | កិរិយាស័ព្ទ | ៦៩ |

| លេខរៀង | មេរៀន | ទំព័រ |
|---|---|---|
| ១៥ | អកម្មកិរិយា សកម្មកិរិយា | ៧១ |
| ១៦ | កាល | ៧៧ |
| ១៧ | វាចក | ៨៥ |
| ១៨ | បុរិសសព្វនាម | ៩៣ |
| ១៩ | វិសេសនសព្វនាម | ១០៦ |
| ២០ | បរិវារស័ព្ទ | ១៣១ |
| ២១ | និបាតស័ព្ទ | ១៣២ |
| ២២ | វណ្ណយុត្តិ | ១៣៦ |
| ២៣ | ខណ្ឌសញ្ញា | ១៤៣ |
| ២៤ | បកិណ្ណកសញ្ញា | ១៤៧ |

រោងពុម្ព
ស៊ុក-ស៊្វី-ស៊ុគាល

តម្លៃ ២០៛០០